# “សហរដ្ឋអាមេរិកផ្តល់ជំនួយចំនួន ២លានដុល្លារ ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា”



” លោក ម៉ាក ស្តីវឡា ភារៈធារីសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា និង លោក យុក ឆាង នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងពិធីចុះហត្ថលេខាផ្តល់ជំនួយ នៅស្ថានទូតសហរដ្ឋអាមេរិកក្នុងទីក្រុងភ្នំពេញ”

នៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០៥ លោក យុក ឆាង នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយជាមួយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ដើម្បីបង្កើតអោយមានកម្មវិធីផ្តល់ជំនួយជាអចិន្ត្រៃយ៍ ។ ជំនួយដែលមានទឹកប្រាក់ចំនួន២លានដុល្លារនេះជាអំណោយពីប្រជាជនសហរដ្ឋអាមេរិក ដើម្បីផ្តល់លទ្ធភាពអោយមជ្ឈមណ្ឌលឯកសារកម្ពុជា បន្តកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការលើកកំពស់ចំណេះដឹង និង ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងសម័យខ្មែរក្រហមកាន់អំណាច ។

លោក ម៉ាក ស្តីវឡា ភារៈធារីនៃស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា បានថ្លែងក្នុងពិធីនោះថា” ជំនួយនេះបញ្ជាក់ឱ្យឃើញកាន់តែច្បាស់ថែមទៀតនូវការប្តេជ្ញាចិត្តយូរអង្វែងរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ”។ ក្រោមកិច្ចព្រមព្រៀងនេះមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងទទួលបានអំណោយប្រចាំឆ្នាំចំនួន ២លានដុល្លារ សំរាប់គាំទ្រដល់ការចំណាយសំរាប់កម្មវិធីជាមូលដ្ឋាន និងកម្មវិធីផ្សេងទៀតដែលមានទិសដៅច្បាស់លាស់ របស់មជ្ឈមណ្ឌល ។

ហេតុនេះមជ្ឈមណ្ឌលឯកសារកម្ពុជា អាចព្យាករណ៍បាននូវចំណូលប្រចាំឆ្នាំដែលគេអាចប្រើប្រាស់សំរាប់រិះរកធនធានបន្ថែម ពីអ្នកផ្តល់ជំនួយ និង អ្នកឧបត្ថម្ភផ្សេងទៀត ។

លោក យ៉ូណាថាន អែដុលតុន នាយកបេសកកម្មទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបាន ធ្វើជាសាក្សីនៅពិធីចុះហត្ថលេខានោះ បានមានប្រសាសន៍ថា " ក្នុងចំណោមអង្គការសង្គមស៊ីវិលទាំងអស់ ដែលបានទទួល ជំនួយពី USAID មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាអង្គការមួយដែលយើងគិតថា នឹងត្រូវបន្តបំរើមនុស្សជំនាន់ក្រោយក្នុង រយៈពេល ២០ឆ្នាំ ៥០ឆ្នាំ ឬក៏១០០ឆ្នាំ នាពេលខាងមុខទៀត"។ យើងមានជំនឿដ៏ស្មោះថាជំនួយនេះ នឹងជួយដល់ មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការសំរេចនូវទស្សនះវិស័យជាមជ្ឈមណ្ឌលអចិន្ត្រៃយ៍មួយ"។ លោក យុគ ឆាង បានថ្លែងថា " មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រៀបដូចជាផ្លូវជាតិលេខ៤ ដែលបានបំរើប្រជាជនរាប់រយពាន់នាក់បន្ទាប់ពីបានសាងសង់រួចរាល់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាកន្លែងដែលអ្នករស់រានពីរបបប្រល័យពូជសាសន៍ និង កូនរបស់កូនគេអាចរំលឹកឡើងវិញនូវ អតីតកាល និង បន្តមកទៀតដោយជីវិតរបស់គេឱ្យកាន់តែប្រសើរឡើងទៅថ្ងៃអនាគត "។

មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាវិទ្យាស្ថានស្រាវជ្រាវឯករាជ្យ ដែលមានដើមកំណើតចេញពីកម្មវិធីប្រល័យពូជសាសន៍ដែល បានបង្កើតឡើងនៅសាកលវិទ្យាល័យយែល ក្នុងឆ្នាំ ១៩៩៥ ដោយមានជំនួយពីរដ្ឋាភិបាលអាមេរិក ។ មជ្ឈមណ្ឌលឯកសារ កម្ពុជា មានគោលបំណងបំរើជូនជាអចិន្ត្រៃយ៍នូវប្រភពពត៌មានមួយដល់ សាធារណៈជនដើម្បីអោយយល់យល់កាន់តែច្បាស់ពី របបខ្មែរក្រហម និងសំរាប់ជនកម្ពុជាឬអ្នកដទៃទៀត ដែលមានបំណងស្វែងរកដំណើរការច្បាប់សំរាប់ការប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្ម សង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តិក្រោមរបបកម្ពុជាប្រជាធិបតេយ្យកាលពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើកាតាឡុកឯកសារសាធារណៈ សំភាសន៍អ្នកដែលមានតួនាទីក្នុងរបប ខ្មែរក្រហម រៀបចំផែនទីទីលានកប់ខ្មោច បង្កើតទស្សនាវដ្តីស្វែងរកការពិត ថែទាំបណ្ណាល័យ រៀបចំស្នូឌីយ៉ូសោតទស្សន៍ រោងពុម្ព និងសាលតាំងពិពណ៌ គ្រប់គ្រងនិងចាត់ចែងវិទ្យាស្ថានហ្វឹកហ្វឺន និងផ្តល់ជំនួយចិត្តសាស្ត្រសង្គមជូនដល់ជន រងគ្រោះដែលទទួល ការធ្វើទារុណកម្មក្នុងរបបខ្មែរក្រហម តាមរយៈគំរោងជនរងគ្រោះដែលទទួលទារុណកម្ម ។

*ពត៌មានបន្ថែម សូមទំនាក់ទំនងការិយាល័យកិច្ចការសាធារណៈរបស់ស្ថានទូតសហរដ្ឋអាមេរិក ទូរស័ព្ទលេខ: ៨៥៥-០២៣- ២១៦ ៤៣៦/៣៨ ។*